**ជនភៀសខ្លួន (refugee)**

ជនភៀសខ្លួន ត្រូវបានផ្តល់ន័យតាមមាត្រា១នៃអនុសញ្ញាស្តីពីឋានៈជនភៀសខ្លួន (1951 UN Convention Relating to the Status of Refugees) ថាជាបុគ្គលភៀសខ្លួនមកក្រៅប្រទេស ដោយមូលដ្ឋានភ័យខ្លាចសមហេតុផល (well-founded fear) នៃការធ្វើទុក្ខបុកម្នេញ (persecution) មូលហេតុមកពីគាត់ជាសមាជិកនៃក្រុមបក្សប្រឆាំង...ហើយដោយសារការភ័យខ្លាចនោះ មិនអាច ឬ មិនមានចេតនាត្រឡប់ទៅទីនោះវិញ ឬមិនសុំការការពារពីរដ្ឋដែលខ្លួនមានសញ្ជាតិនោះ។

និយមន័យនេះ ត្រូវបានគេមើលឃើញថាចង្អៀត។ ក្រោយមកមានលិខិតូបករណ៍អន្តរជាតិតំបន់ ដែលជាអនុសញ្ញា និងសេចក្តីប្រកាស បានពង្រីកនិយមន័យ ជនភៀសខ្លួន ក្តោបអ្នកដែលភៀសខ្លួនចេញពីសង្គ្រាម ឬការបំពានសិទ្ធិមនុស្សទ្រង់ទ្រាយធំ។ ក្នុងករណីខ្លះ ភៀសខ្លួនទៅកាន់តំបន់មួយផ្សេងក្នុងប្រទេសដដែល ដែលគេហៅថា internal refugee ឬ internally displaced persons ក៏ត្រូវបានចាត់ថាជាជនភៀសខ្លួនដែរ។

**ខ្លឹមសារបន្ថែម៖** ពាក្យ "ការធ្វើទុក្ខបុកម្នេញ" មិនត្រូវបានផ្តល់ន័យទេ ដោយគ្រាន់តែផ្តល់ជាសញ្ញាណ សំដៅលើការបំពានសិទ្ធិមនុស្សចម្បង (fundamental rights) ដោយរើសអើង។ ការភ័យខ្លាចត្រូវតែមានភស្តុតាងបញ្ជាក់រឹងមាំ។ តាមទ្រឹស្តី រដ្ឋមានតួនាទីការពារប្រជាពលរដ្ឋ ក្នុងករណីដែលរដ្ឋខ្លួនឯង ធ្វើបាបប្រជាជនខ្លួនឯងពិតជាចម្លែក ដែលទាមទារឲ្យរដ្ឋដទៃជួយ តាមរយៈការសុំសិទ្ធិជាជនភៀសខ្លួន។ វាអាចមានករណី ដែលរដ្ឋមិនបំពាន តែរដ្ឋគ្មានសមត្ថភាពក្នុងការការពារ ការធ្វើទុក្ខបុកម្នេញពីក្រុមផ្សេង។ ជាចុងក្រោយ បើជននោះមានសញ្ជាតិពីរ ហើយរដ្ឋនោះ អាចការពារខ្លួនបាន ជននោះនឹងមិនមែនជាជនភៀសខ្លួនក្នុងប្រទេសទីបីទេ។